ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

# បទបង្ហាញស្តីពី

## លទ្ធផលការងារក្នុងឆ្នាំ ២០២២ និងលើកទិសដៅការងារបន្ត របស់នាយកដ្ឋានថែទាំសុខភាពជនបទ

## ឆ្នាំ ២០២២

# មាតិកា

I. សេចក្តីផ្តើម
II. សមិទ្ធផលសម្រេចបាន
III.បញ្ហាប្រឈម
IV. មេរៀននិងបទពិសោធន៍
- ១. ចំណុចខ្លាំង
- ២. ចំណុចខ្វះខាត
- ៣. សំណូមពរ

V. ទិសដៅនិងផែនការបន្ត
VI. សេចក្តីសន្និដ្ឋាន

# I. សេចក្តីផ្តើម

- អនាម័យជាបញ្ហាសុខភាពសាធារណៈ កង្វះអនាម័យបណ្តាលឲ្យមានការចម្លងរោគពីលាមកមកមាត់មនុស្ស ហើយស្តែងចេញជាជំងឺ៖

- ជំងឺរាកនិងជំងឺដង្កូវពោះវៀន
- ប៉ះពាល់ផលិតភាពការងារ
- ការសិក្សារៀនសូត្រ
- ចំណូលសេដ្ឋកិច្ចគ្រួសារនិងពេលវេលា
- ភាពក្រីក្រ








- ដូច្នេះដើម្បីសម្រេចបានតាមផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់អនាម័យនៅជនបទឆ្នាំ (២០២៣ -២០២៤) និងទស្សនវិស័យនៃគោលនយោបាយជាតិ២០២៥ចាំបាច់ត្រូវលើកកម្ពស់ការប្រតិបត្តិអនាម័យនៅសហគមន៍ជនបទដោយអនុវត្តនូវសារបើសំខាន់ៗរួមមាន៖



ការប្រើប្រាស់បង្គន់អនាម័យ



មានទម្លាប់លាងសម្អាតដៃជាមួយសាប៊ូក្រោយពេលបន្ទោបង់ និងមុនបរិភោគអាហារ



ហូបទឹកមានសុវត្ថិភាព

# ➢គោលដៅក្នុងសកម្មភាពជំរុញការលើកកម្ពស់អនាម័យជនបទ



## ➤អត្រាគ្របដណ្តប់អនាម័យក្នុងប្រទេសកម្ពុជានិងទិសដៅឆ្នាំ២០២៣-២០២៥




ប្រភព៖ CSES, MoP, 2020

## ➢ កម្មវិធីលើកកម្ពស់អនាម័យជនបទគាំទ្រដោយថវិកាជាតិឆ្នាំ២០២២

- ថវិកាដែលក្រសួងផ្តល់ជូននាយកដ្ឋានថែទាំសុខភាពជនបទក្នុងឆ្នាំ២០២២ មានចំនួន ២,៣៨៤.០ លានរៀល
- ថវិកាទាំងនេះបានប្រើប្រាស់ក្នុងសកម្មភាពជម្រុញសេវាអប់រំសុខភាពអនាម័យជនបទដូចខាងក្រោម៖
  - ➢ អនុកម្មវិធីទី២.៣៖ ការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធរូបវន្តអនាម័យជនបទ
  - ➢ អនុកម្មវិធីទី២.៤៖ ការលើកកម្ពស់ការរស់នៅស្អាត ការអប់រំសុខភាព និងអនាម័យជនបទ

# II. សមិទ្ធផលសម្រេចបានឆ្នាំ២០២២

## ៩. សកម្មភាពរៀបចំប្រជុំ ចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗ

- ប្រធាននាយកដ្ឋាននិងសហការីបានរៀបចំប្រជុំ ចូលរួមប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកម្មវិធីផ្សេងៗចំនួន១០៤លើកដោយផ្តោតសំខាន់លើ៖
  - ការចុះផ្តល់សម្ភារៈអនាម័យជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត
  - វេទិកាចែករំលែកចំណេះដឹងស្តីពីការសាងសង់បង្គន់និងអនាម័យក្នុងបរិស្ថានប្រឈម
  - ពិធីប្រកាសភូមិឃុំស្រុកនិងខេត្តបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល (ODF)
  - ចុះពិនិត្យតាមដានការប្រើប្រាស់បង្គន់អនាម័យក្នុងអង្គភាពរដ្ឋនិងសេវាឯកជនតាមខេត្ត
  - រៀបចំសិក្ខាសាលាថ្នាក់ជាតិផ្សព្វផ្សាយគោលការណ៍ណែនាំការផ្ទៀងផ្ទាត់ភូមិឃុំស្រុកខេត្ត (ODF)
  - រៀបចំប្រជុំថ្នាក់ក្រោមជាតិនិងជាមួយអង្គការដៃគូស្តីពីការពន្លឿន (ODF) នៅកម្ពុជា
  - ចុះជម្រុញការសាងសង់បង្គន់ និងចែកសម្ភារៈបង្គន់អនាម័យដល់គ្រួសារក្រីក្រ
  - បើកវគ្គតម្រង់ទិសកម្មវិធី CLTS ដល់មន្ត្រីថ្នាក់ក្រោមជាតិនិងអង្គការក្រៅរដ្ឋាភិបាល

# រូបភាពសកម្មភាពការងារប្រធាននាយកដ្ឋាននិងសហការី



**រូបភាពទី១៖** ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងពិធីប្រកាសខេត្តស្វាយរៀងជាខេត្ត ODF ២៧ មេសា ២០២២



**រូបភាពទី២៖** សកម្មភាពចាប់ឆ្នោតជ្រើសរើសភូមិឃុំស្រុកនិងក្រុងដើម្បីចុះពិនិត្យមើលការប្រើប្រាស់បង្គន់អនាម័យនិងការប្រើប្រាស់ទឹក



**រូបភាពទី៣៖** ពិធីប្រកាសស្រុកស្រីស្នំខេត្តសៀមរាបជាស្រុក ODF ១៨ វិច្ឆិកា ២០២២



**រូបភាពទី៤៖** សិក្ខាសាលាស្តីពីការពន្លឿន ODF នៅ ខេត្តកែប ១៥ សីហា ២០២២

# ២. សកម្មភាពកម្មវិធីគ្រប់គ្រងទិន្នន័យផ្គត់ផ្គង់ទឹកស្អាតនិងសុខភាពអនាម័យជនបទ (MIS)

- អនុប្រធាននាយកដ្ឋាននិងសហការីបានរៀបចំសិក្ខាសាលា ចូលរួមប្រជុំ និងកម្មវិធីផ្សេងៗចំនួន៥៦ លើកដោយផ្តោតសំខាន់លើ៖
  - រៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងការគ្រប់គ្រងប្រព័ន្ធទិន្នន័យ(MIS)បែបឌីជីថលក្នុងវិស័យផ្គត់ផ្គង់ទឹកការសំអាត និងលើកកម្ពស់អនាម័យសម្រាប់មន្ត្រីថ្នាក់ជាតិនឹងថ្នាក់ខេត្ត
  - ប្រជុំប្រមូលទិន្នន័យនៃការធ្វើសារពើភ័ណ្ឌទិន្នន័យនិងការគ្រប់គ្រងទិន្នន័យតាមប្រព័ន្ធឌីជីថល (AIMIS)
  - ប្រជុំជាមួយអង្គការដៃគូ (SWA, UNICEF, WaterAid) ដើម្បីពិនិត្យ និងវាយតម្លៃលទ្ធផលប្រចាំឆ្នាំ
  - បណ្តុះបណ្តាលសិក្ខាកាមថ្នាក់ជាតិនិងថ្នាក់ខេត្តលើការគ្រប់គ្រងទិន្នន័យMISបែបឌីជីថលតាមរយៈGoogle Data Studio ចំនួន ២៥ រាជធានី-ខេត្តមានអ្នកចូលរួមសរុប២៤៤នាក់
  - បានប្រមូលនិងចងក្រងទិន្នន័យសំខាន់ៗសម្រាប់វិស័យWASH និងវិស័យផ្គត់ផ្គង់ទឹកនិងអនាម័យសម្រាប់ឆ្នាំ ២០២២
  - បានរៀបចំផ្ទាំងព័ត៌មានទិន្នន័យ (Dashboard) ជាភាសាខ្មែរ និងអង់គ្លេសក៏ដូចជា Web-portal ជាមួយក្រុមហ៊ុនBikay

# រូបភាពសកម្មភាពក្រុមការងារគ្រប់គ្រងទិន្នន័យ MIS



**រូបភាពទី១៖** សិក្ខាសាលាថ្នាក់ជាតិស្តីពីការគ្រប់គ្រងទិន្នន័យ MIS នៅភ្នំពេញ ៣០-៣១ ឧសភា ២០២២



**រូបភាពទី២៖** សិក្ខាសាលាថ្នាក់ខេត្តស្តីពីការគ្រប់គ្រងទិន្នន័យ MIS នៅខេត្តសៀមរាប ៩-១០ មិថុនា ២០២២



**រូបភាពទី៣៖** សិក្ខាសាលាថ្នាក់ខេត្តស្តីពីការគ្រប់គ្រងទិន្នន័យ MIS នៅខេត្តស្ទឹងត្រែង ១៤-១៥ មិថុនា ២០២២



**រូបភាពទី៤៖** សិក្ខាសាលាថ្នាក់ខេត្តស្តីពីការគ្រប់គ្រងទិន្នន័យ MIS នៅខេត្តព្រះវិហារ ៧-៨ មិថុនា ២០២២

## ៣. សកម្មភាពកម្មវិធីលើកកម្ពស់អនាម័យជនបទតាមរយៈ (ថវិកាកម្មវិធី)

- មន្ត្រីនាយកដ្ឋានបានចុះផ្សព្វផ្សាយនិងបើកវគ្គបណ្តុះបណ្តាលចំនួន២២លើកដោយផ្តោតសំខាន់លើ៖
  - ការផ្សព្វផ្សាយស្តីពីការលើកកម្ពស់អនាម័យជនបទតាមរយៈវិទ្យុចំនួន០៣លើក
  - រៀបចំវគ្គបណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពជនបង្គោលអនាម័យចំនួន០៣លើកមានអ្នកចូលរួម១៣២នាក់
  - ចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឲ្យប្រតិបត្តិអនាម័យនៅតាមគ្រួសារទាំង១៦ខេត្ត និងពិនិត្យទីតាំងដាក់បង្គន់ចំនួន១៣ខេត្ត
  - ចុះផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្តីពីអនាម័យក្នុងបរិស្ថានប្រឈមចំនួន០៦ខេត្តមានអ្នកចូលរួមចំនួន១៧០នាក់
  - បានសាងសង់បង្គន់អនាម័យសរុបចំនួន២៧១៩បង្គន់ក្នុងឆ្នាំ២០២២ក្រោមថវិការដ្ឋ

# រូបភាពសកម្មភាពកម្មវិធីលើកកម្ពស់អនាម័យជនបទតាមរយៈថវិកាកម្មវិធី



រូបភាពទី១៖ សកម្មភាពចុះផ្សព្វផ្សាយគោលការណ៍ណែនាំក្នុងការលើកកម្ពស់អនាម័យជនបទ



រូបភាពទី២៖ សកម្មភាពចុះផ្សព្វផ្សាយគោលការណ៍ណែនាំក្នុងការលើកកម្ពស់អនាម័យជនបទ



រូបភាពទី៣៖ សកម្មភាពចុះត្រួតពិនិត្យមើលការសាងសង់និងប្រើប្រាស់បង្គន់អនាម័យតាមភូមិ



រូបភាពទី៤៖ សកម្មភាពចុះត្រួតពិនិត្យមើលការសាងសង់និងប្រើប្រាស់បង្គន់អនាម័យតាមភូមិ

# ៤. សកម្មភាពកម្មវិធីសហគមន៍ដឹកនាំអនាម័យ CLTS (ថវិកាUNICEF)

- មន្ត្រីនាយកដ្ឋានបានរៀបចំប្រជុំ បើកវគ្គបណ្តុះបណ្តាល ចូលរួមប្រជុំ និងសិក្ខាសាលាចំនួន៧០លើក ដោយផ្តោតសំខាន់លើ៖
  - ចុះបំផុសនិងជម្រុញការងារសាងសង់បង្គន់អនាម័យនិងផ្សព្វផ្សាយពីកម្មវិធីទឹកស្អាតនិងអនាម័យសម្រាប់ជនពិការនិងមនុស្សចាស់
  - បណ្តុះបណ្តាលការសាងសង់បង្គន់អនាម័យលូភ្ជោះលើផ្ទះ
  - ចុះបំផុសសកម្មភាពអនាម័យតាមខ្នងផ្ទះនិងប្រមូលព័ត៌មានទីផ្សារអនាម័យ
  - ចុះផ្សព្វផ្សាយគោលការណ៍ណែនាំជាតិស្តីពីការអនុវត្ត (CLTS) និងអនាម័យក្នុងបរិស្ថានប្រឈម
  - ប្រជុំជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តនិងអង្គការដៃគូពិភាក្សាគោលការណ៍ឧបត្ថម្ភធនសាងសង់បង្គន់អនាម័យដល់គ្រួសារក្រីក្រ
  - ចុះសិក្សាទីតាំងសាងសង់បង្គន់អនាម័យតាមព្រំដែនសម្រាប់ពលករចំណាកស្រុកទៅប្រទេសថៃ
  - ប្រជុំក្រុមការងារ PWG-RWSSH ស្តីពីស្ថានភាពទឹកស្អាតនិងអនាម័យ ការផ្ទៀងផ្ទាត់ភូមិឃុំស្រុកខេត្ត (ODF)
  - បានសាងសង់បង្គន់អនាម័យសរុបចំនួន២៦០៣៦បង្គន់ក្នុងឆ្នាំ២០២២ក្នុងខេត្តចំនួន០៦ (ថវិកា Unicef)

# រូបភាពសកម្មភាពកម្មវិធីសហគមន៍ដឹកនាំអនាម័យ CLTS



**រូបភាពទី១៖** សកម្មភាពប្រជុំ PWG-RWSSH នៅខេត្តក្រចេះ ១២ តុលា ២០២២



**រូបភាពទី២៖** សកម្មភាពប្រជុំ PWG-RWSSH នៅខេត្តរតនគិរី ១៣ តុលា ២០២២



**រូបភាពទី៣៖** សកម្មភាពប្រជុំ PWG-RWSSH នៅខេត្តព្រះវិហារ ១៤ តុលា ២០២២



**រូបភាពទី៤៖** ប្រជុំពិនិត្យលទ្ធផលបានអនុវត្តពីទឹកស្អាតនិងអនាម័យឆ្នាំ ២០២២ និងផែនការឆ្នាំ២០២៣ នៅខេត្តក្រចេះ ១៤ ធ្នូ ២០២២

# ៥. សកម្មភាពការងារ Facebook និងអង្គការ East Meet West (EMW)

- មន្ត្រីនាយកដ្ឋានបានផ្សព្វផ្សាយលើកកម្ពស់អនាម័យជនបទសម្រេចបានលទ្ធផលដូចខាងក្រោម៖
  - បានផ្សព្វផ្សាយវីដេអូសារអប់រំអនាម័យនិងវិធានការទប់ស្កាត់ជំងឺកូវីដ១៩ក្នុងខេត្តគោលដៅទាំង០៦ របស់អង្គការ Unicef តាមរយៈគេហទំព័រ Facebook របស់នាយកដ្ឋានថែទាំសុខភាពជនបទ
  - មន្ត្រីនាយកដ្ឋានបានសហការជាមួយអង្គការ (EMW) ចុះផ្សព្វផ្សាយនិងជម្រុញការងារសាងសង់បង្គន់អនាម័យដល់គ្រួសារក្រីក្រក្នុងឆ្នាំ២០២២សរុបចំនួន១៥៣៣បង្គន់ (ថវិកាអង្គការ EMW)

# រូបភាពសកម្មភាពការងារ Facebook និងអង្គការ EMW



**រូបភាពទី១៖** ចុះផ្សព្វផ្សាយសារអប់រំអនាម័យនិងការណែនាំពីគេហទំព័រ Facebook របស់នាយកដ្ឋានថែទាំសុខភាពជនបទទៅអាជ្ញាធរឃុំ



**រូបភាពទី២៖** ចុះផ្សព្វផ្សាយសារអប់រំអនាម័យនិងការណែនាំពីគេហទំព័រ Facebook របស់នាយកដ្ឋានថែទាំសុខភាពជនបទទៅអាជ្ញាធរឃុំ



**រូបភាពទី៣៖** សកម្មភាពកែលំអរការសាងសង់បង្គន់លូ១ជួរទៅលូ២ជួរ របស់អង្គការ EMW



**រូបភាពទី៤៖** សកម្មភាពកែលំអរការសាងសង់បង្គន់លូ១ជួរទៅលូធ្លាស់២ជួររបស់អង្គការ EMW

# III. បញ្ហាប្រឈម

- ប្រជាពលរដ្ឋនៅតែមានទស្សនៈពឹងផ្អែកលើជំនួយទើបនាំគ្នាសាងសង់បង្គន់អនាម័យ
- ប្រជាជនក្រីក្រនៅមិនទាន់បានទទួលផលប្រយោជន៍ច្រើនពីកម្មវិធីលើកកម្ពស់អនាម័យ
- ការអនុវត្តគម្រោងប្រចាំឆ្នាំដែលគាំទ្រដោយថវិកាជាតិមានរយៈពេលខ្លី
- ឥរិយាបទប្រឈមនិងគ្រោះថ្នាក់ពេលបន្ទោបង់ពាសវាលពាសកាល មិនទម្លាប់ផឹកទឹកមានសុវត្ថិភាព និងការលាងសំអាតដៃមិនបានត្រឹមត្រូវ
- ទីផ្សារអនាម័យនៅមានកម្រិត (បច្ចេកវិទ្យា ផលិតផល និងការផ្គត់ផ្គង់បរិក្ខាអនាម័យ)
- សមត្ថភាពចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- តំបន់ខ្លះមានភាពលំបាក ខ្វះទឹក ឬគ្រោះធម្មជាតិ
- ការរីករាលដាលជំងឺកូវីដ១៩
- ការធ្លាក់ចុះប្រភពថវិកាជាតិនិងពីអង្គការដៃគូនានាក្នុងការអនុវត្តកម្មវិធីអនាម័យជនបទ

# IV. មេរៀនបទពិសោធន៍

## ១. ចំណុចខ្លាំង

- មានយុទ្ធសាស្ត្រ ទិសដៅ និងផែនការច្បាស់លាស់ក្នុងការលើកកម្ពស់អនាម័យជនបទ
- ខិតខំឲ្យមានការគាំទ្រទាំងថវិកាគោលនយោបាយយុទ្ធសាស្ត្រ និងឆន្ទៈគាំទ្រដល់បញ្ហាលើកកម្ពស់អនាម័យជនបទ
- មានការគាំទ្រ និងសហការល្អ ពីដៃគូអភិវឌ្ឍទាំងថវិកា បច្ចេកទេស លើការអនុវត្តគម្រោង ការចែករំលែកបទពិសោធន៍ និងព័ត៌មាននានា
- មានការអភិវឌ្ឍឯកសារ និងគោលការណ៍ផ្សេងៗ ក្នុងការដឹកនាំអនុវត្តគម្រោងនានានៃការលើកកម្ពស់អនាម័យជនបទ
- បុគ្គលិកម្នាក់ៗក្នុងនាយកដ្ឋានមានឆន្ទៈខ្ពស់ក្នុងការរួមគ្នាធ្វើការជំរុញនិងលើកកម្ពស់អនាម័យជនបទ

## ២. ចំណុចខ្វះខាត

- ការចូលរួមផ្តល់សេវារបស់វិស័យឯកជននៅមានកម្រិត
- ថវិការរដ្ឋនៅមានកម្រិតដើម្បីគាំទ្រវិស័យលើកកម្ពស់អនាម័យជនបទ
- ពេលវេលាអនុវត្តគម្រោងប្រចាំឆ្នាំ ដែលគាំទ្រដោយថវិការរដ្ឋមានរយៈពេលខ្លី
- ការគាំទ្រ និងការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត
- ខ្វះខាតផ្នែកធនធានមនុស្សដែលមានជំនាញនិងបទពិសោធន៍
- គម្រោងខ្លះមានការថយចុះការគាំទ្រផ្នែកហិរញ្ញវត្ថុពីអង្គការដៃគូអភិវឌ្ឍ

# ៣. សំណូមពរ

- ស្នើសុំថ្នាក់ដឹកនាំជួយគៀរគររកធនធានពីថវិការជាតិនិងអង្គការដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រកម្មវិធីនានាស្ថិតនៅក្រោមនាយកដ្ឋានដើម្បីបានបន្តដំណើការ

- រៀបចំការផ្សព្វផ្សាយផែនការសកម្មភាពជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទឲ្យបានទូលំទូលាយដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធ

- ការអនុវត្តកម្មវិធីលើកកម្ពស់អនាម័យដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍នានាត្រូវផ្អែកលើផែនការសកម្មភាពជាតិក្នុងការជម្រុញលើកកម្ពស់អនាម័យជនបទ

## V. ទិសដៅនិងផែនការបន្ត

- បន្តប្រជុំការងារបច្ចេកទេសMISថ្នាក់ជាតិនិងជាមួយអង្គការដៃគូដើម្បីប្រមូលនិងចងក្រងទិន្នន័យMIS
- បន្តផ្សព្វផ្សាយផែនការសកម្មភាពជាតិស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទ
- បន្តរៀបចំឯកសារគោលការណ៍ណែនាំ ស្តីពីការផ្គត់ផ្គង់ទឹកនិងអនាម័យជនបទដែលបានសហការជាមួយអង្គការ WaterAid សម្រាប់គាំទ្រដល់គ្រួសារក្រីក្រ
- រៀបចំផ្សព្វផ្សាយផែនការសកម្មភាពជាតិជំហានទី០២ (២០១៩-២០២៣)ស្តីពីការផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទនៅតាមបណ្តាខេត្តឲ្យបានទូលំទូលាយ
- បន្តកិច្ចសហការជាមួយអង្គការ IDE, Unicef, Plan, WaterAid និងEMW លើកម្មវិធីអនាម័យនៅតាមបណ្តាខេត្តគោលដៅ
- បន្តបណ្តុះបណ្តាលពីទឹកស្អាតនិងអនាម័យដែលមានភាពធន់ទ្រាំទៅនឹងអាកាសធាតុ
- បន្តចូលរួមពិភាក្សាការរៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងអនាម័យនិងកុមារីពេលមានរដូវ

# VI. សេចក្តីសន្និដ្ឋាន

ការអនុវត្តកម្មវិធីលើកកម្ពស់អនាម័យគឺជាសកម្មភាពមួយដែលទាមទារពេលវេលាវែងពីព្រោះយើងត្រូវធ្វើការផ្លាស់ប្តូរទម្លាប់និងផ្នត់គំនិតរបស់ប្រជាជន។ទន្ទឹមនេះការអនុវត្តការងារទាមទាឲ្យមានការសម្របសម្រួលនិងឯកភាពគ្នាពីគ្រប់ភាគីពាក់ព័ន្ធដើម្បីជំរុញ និងលើកកម្ពស់អនាម័យនៅជនបទឲ្យមានភាពរលូន។

ដើម្បីឱ្យការអនុវត្តការងារនេះកាន់តែមានភាពល្អប្រសើរនិងប្រសិទ្ធភាពខ្ពស់នាយកដ្ឋានថែទាំសុខភាពជនបទនឹងបន្តកែលម្អគុណភាពកម្មវិធីផ្គត់ផ្គង់ទឹក ការសំអាត និងអនាម័យជនបទប្រកបដោយនិរន្តរភាព ក្នុងក្របខ័ណ្ឌសហប្រតិបត្តិការរវាងដៃគូពាក់ព័ន្ធដូចជា ម្ចាស់ជំនួយ ភ្នាក់ងាររដ្ឋាភិបាល និងប្រជាជនមូលដ្ឋាន និងជាពិសេសបន្តការអនុវត្តយុទ្ធសាស្ត្រជាតិឲ្យបានទូលំទូលាយ និងស៊ីជម្រៅគ្របដណ្តប់ទូទាំងប្រទេស។

# សូមអរគុណ!